# បរិញ្ញាប័ត្របានពីភាគសំរាម

ដោយៈអាចម៍ផ្កាយ

តាមធម្មតា ខ្ញុំមិនចូលចិត្តជិះម៉ូតូលឿនទេ។ នៅព្រឹកថ្ងៃមួយ ខណៈដែលខ្ញុំជិះម៉ូតូទៅធ្វើការ ពេលមកដល់ភ្លើងស្តុបត្រង់ផ្លូវបំបែក ខ្ញុំឃើញស្ត្រីចំនាស់ម្នាក់ កំពុងខំដើរទប់ខ្លួនយ៉ាងពិបាកលើចិញ្ចើមថ្នល់។ ដៃគាត់ម្ខាងកាន់អំបោស ឯដៃម្ខាងទៀត កាន់ប្រដាប់ប្រមូលសំរាម។ មើលទៅគាត់ ដូចជាកំពុងរកកល់នឹងដួល។ ខ្ញុំប្រញាប់ចតម៉ូតូចោល ហើយរត់ទៅជួយទប់គ្រាខ្លួនគាត់ យ៉ាងរហ័ស។

«លោកអ៊ំ! លោកអ៊ំ!... យី! លោកអ៊ំយ៉ាងម៉េចហ្នឹង?»

ខ្ញុំសង្កេតឃើញទឹកមុខរបស់អ៊ំស្រីម្នាក់នោះ ឡើងខៀវស្លេកស្លាំង គ្មានឈាមមួយដំណក់។ ខ្ញុំអាចដឹងភ្លាមថា មុននេះគាត់ស្ទើរតែដួលសន្លប់ទៅហើយ ដោយសារពេគខ្យល់។ មិនដឹងធ្វើម៉េច ខ្ញុំក៏ស្រែកហៅអ្នកធ្វើដំណើរទាំងឡាយ ដែលបញ្ឈប់យានយន្តរង់ចាំភ្លើងស្តុបឲ្យជួយ។

«ជួយផង! មកជួយគាត់ផង... គាត់ខ្យល់គហើយ! ជួយយកគាត់ទៅមន្ទីរពេទ្យផង!!!»

ខ្ញុំខកចិត្ត និងសោកស្តាយជាខ្លាំងដែលគិតខុស ទាំងម៉ូតូទាំងរថយន្ត បើកចេញទៅធ្វើព្រងើយ។ ពួកគេបានត្រឹមតែងាកមើលប៉ុណ្ណោះ។ ខ្ញុំចាប់ត្រកងយករាងកាយដ៏ស្គមរបស់គាត់ មកឲ្យអង្គុយទម្រេតខ្លួនក្រោមម្លប់ឈើលើចិញ្ចើមថ្នល់ ហើយចាប់យកក្រដាសឯកសារ ក្នុងកាតាបមកបក់ឲ្យគាត់។

«លោកអ៊ំ! លោកអ៊ំ!... លោកអ៊ំយ៉ាងម៉េចហើយ? បានឮខ្ញុំនិយាយទេ?... លោកអ៊ំ!... លោកអ៊ំ!!!...»

ឃើញហេតុមិនស្រួល ខ្ញុំគិតតែម្យ៉ាង គឺត្រូវនាំគាត់ទៅមន្ទីរពេទ្យ។ ខណៈដែលខ្ញុំកំពុងដើបទៅរកហៅរ៉ឺម៉កតុក!តុក! មកដឹកគាត់ទៅ គាត់ក៏ស្រែកឡើង...

«អូ៎យ!... មិនបាច់ទេ... កុំ! កុំទៅអី...អឺ...ខ្ញុំធូរគ្រាន់បើហើយ...»

«អ្ហ៎! អ៊ំដឹងខ្លួនហើយ!?...ក្មួយគិតថាទៅមន្ទីរពេទ្យល្អជាង!»

«ទេ! មិនអីទេ...ខ្ញុំធ្លាប់ខ្ញុំស៊ាំអស់ទៅហើយ សំរាកតែបន្តិចទៅលែងអីហើយ!»

ប្លែកចិត្តបន្តិចដែរ... គាត់និយាយជាមួយខ្ញុំ ប្រើសុទ្ធតែពាក្យ «ខ្ញុំ!ខ្ញុំ!» យ៉ាងទន់ផ្អែមពិរោះណាស់។ តែសម្រាប់ខ្ញុំ វាមានន័យគោរព និងអោនលំទោនពេកហើយ ទាំងដែលគាត់ក៏មានអាយុច្រើនចាស់ស្មើម្តាយ ឬស្មើអ៊ំរបស់ខ្ញុំទៅហើយ!

«ឱ!លោកអ៊ំ... មិនចាំបាច់និយាយពាក្យ«ខ្ញុំ!ខ្ញុំ!»ទេ ព្រោះខ្ញុំក៏មានអាយុស្របាលៗនឹងកូន ឬក្មួយរបស់អ៊ំដែរ។»

«អូ៎! អរគុណច្រើន... ខ្ញុំ... អ៎... អ៊ំរាងធូរគ្រាន់បើហើយ! ក្មួយពិតជាមានសន្តានចិត្តល្អមែន។»

ខ្ញុំទទួលអារម្មណ៍ថា ពេញចិត្តយ៉ាងខ្លាំង ចំពោះពាក្យសរសើរនេះ។

«មិនជាអ្វីទេលោកអ៊ំ! និយាយអ៊ីចឹង អ៊ំធ្វើការនៅទីនេះមែនទេ?»

«មែនហើយ!... អ៊ំបោសសំរាមតាមថ្នល់, ស៊ីឈ្នួលកាត់ស្មៅ, ស៊ីឈ្នួលលាងចានតាមរោងការ ឬរោងបុណ្យផ្សេងៗ, ស៊ីឈ្នួលលាបរបងផ្ទះ, ជូតផ្ទះ, ស្រោចផ្កាដាំផ្កា, និងការងារមេផ្ទះគ្រប់បែបយ៉ាង អ៊ំអាចធ្វើបានទាំងអស់។»

ខ្ញុំបានទទួលចម្លើយយ៉ាងវែង ដោយមិនចាំបាច់សួរលម្អិត ព្រោះគាត់ធ្លាប់និយាយពីការងារដែលគាត់អាចធ្វើបាន ឲ្យគ្រប់ៗគ្នាដឹង ដើម្បីបង្ហាញខ្លួនប្រាប់គេឯងឲ្យជ្រាបថា គាត់ត្រូវការការងារធ្វើ។ ខ្ញុំមិនធ្លាប់គិតសោះថា ស្រ្តីមាឌតូចបែបនេះអាចធ្វើការងារបានច្រើន ហើយធ្ងន់ធ្ងរដល់ថ្នាក់ហ្នឹង! ខ្ញុំគិតអាណិតគាត់ណាស់ដែរ ព្រោះមើលទៅក៏ឃើញថា គាត់ជាអ្នកក្រីក្រតោកយ៉ាកយ៉ាងខ្លាំង។

«បើអ៊ុំចឹងអ៊ំមិនមានកូន និងប្តីទេឬ? សុំអភ័យទោស! ក្មួយសួរបែបនេះ អ៊ំមិនថាអីទេ?»

«មិនអីទេ! អ៊ំមានកូនពីរនាក់ ឯប្តីអ៊ំ គាត់ស្លាប់យូរហើយ។ ថ្ងៃស្អែកនេះកូនច្បងអ៊ំគេនឹងរៀនចប់ហើយ ហើយឮថាបានទទួលសញ្ញាប័ត្រស្អីមិនដឹងទេ!... ឮតែ... បរិ... អឺ... បរិ...

«បរិញ្ញាប័ត្រ!»

«ចាំ... មែនហើយ! តែអ៊ំក៏ប្រហែលជាមិនបានទៅចូលរួមទេ... ព្រោះជាប់ការងារច្រើនណាស់!... តែ... អឺ...

«តែអីអ៊ំ? និយាយមកចុះ! បើខ្ញុំជួយបានខ្ញុំនឹងជួយ!»

«មែនអេះ!? ក្មួយពិតជាជួយអ៊ំមែន? ក្មួយជាមនុស្សល្អណាស់!... បើអ៊ុំចឹងស្អែកក្មួយទៅធ្វើការទៀតទេ? ហើយមកតាមផ្លូវនេះដដែលទេ?... អ៊ំធ្វើការនៅផ្លូវនេះរាល់ៗព្រឹក។

«បាទ! ថ្ងៃស្អែកខ្ញុំក៏ទៅធ្វើការដូចធម្មតាអ៊ីចឹង ហើយមកតាមផ្លូវនេះដដែលទេ។»

«អឺ... បើអ៊ុំចឹងឆៀងចូលជួបអ៊ំ នៅទីនេះបន្តិចផង អ៊ំនឹងមករង់ចាំណា!»

ខ្ញុំក៏នឹកឆ្ងល់ណាស់ដែរ ចំពោះសំណើរបស់គាត់ តែក៏ដល់ម៉ោងទៅធ្វើការទៅហើយ ទើបមិនប្រញាប់សួររកហេតុផលអ្វី។ ថ្ងៃនេះ ទោះជាទៅធ្វើការយឺតបន្តិចក៏ដោយ ក៏ខ្ញុំទទួលអារម្មណ៍ថាសប្បាយចិត្តយ៉ាងខ្លាំង ដែលបានជួយយកអាសារលោកអ៊ំចំនាស់ម្នាក់នោះ។

***

ថ្ងៃបន្ទាប់មក ខ្ញុំក៏មកជួបគាត់តាមសន្យា។ អ៊ំស្រីសប្បាយចិត្តយ៉ាងខ្លាំង នៅពេលដែលឃើញខ្ញុំ។ គាត់កាន់បាច់ផ្កាកុលាបមួយបាច់ធំ។ ខ្ញុំគិតសង្ស័យក្នុងចិត្តដែរ តែមិនទាន់សួរផង គាត់ក៏ប្រាប់មុន។

«លោកក្មួយអើយ! ឲ្យអ៊ំសុំពឹងយកបាច់ផ្កានេះ ទៅឲ្យកូនប្រុសរបស់អ៊ំផង។ ថ្ងៃនេះគេទទួល... អឺ... ទទួលបរិញ្ញាប័ត្រផង តើក្មួយអាចជួយបានទេ?»

«បរិញ្ញាប័ត្រ!!! ហេតុអីលោកអ៊ំ មិនអញ្ជើញទៅដោយខ្លួនឯង?»

ខ្ញុំឆ្ងល់ព្រោះគិតថា កូនគាត់ពិតជាសប្បាយចិត្ត ប្រសិនបើបានទទួលបាច់ផ្កានេះពីម្ដាយគេផ្ទាល់ ហើយគាត់ក៏...

«អ៊ំមិនហ៊ានទៅទេ!... ម្យ៉ាងអ៊ំរវល់ផង ក៏គង់នឹងទៅមិនកើត ទើបបានជាសុំចិត្តក្មួយ ឲ្យជួយអ៊ំផង តើបានទេ?»

ខ្ញុំងក់ក្បាលទទួលពាក្យ ព្រមទាំងទទួលយកបាច់ផ្កាពីគាត់។

«កូនប្រុសអ៊ំឈ្មោះអីដែរ?»

«ឈ្មោះសរ ខេមរិន្ទ! ម៉ោងពីររសៀលនេះ គេនឹងចាប់ផ្ដើមពិធីហើយ។»

ណ្ហើយចុះ! ខ្ញុំក៏គិតថាល្អម្យ៉ាងដែរ រាប់ថាជាការសម្ដែង សេចក្ដីត្រេកអរសាទរនឹងប្អូនធម៌ ដែលនៅមិនទាន់ស្គាល់មុខ! ថ្ងៃនោះនៅការិយាល័យ មានមិត្តភ័ក្តិច្រើនគ្នាសួរថាយកបាច់ផ្កាទៅឲ្យនរណា? ខ្ញុំក៏ឆ្លើយថា «អូ៎!ថ្ងៃនេះប្អូនប្រុសខ្ញុំ ទទួលបរិញ្ញាប័ត្រអក្សរសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។»

***

ខ្ញុំព្យាយាមប្រជ្រៀតហ្វូងមនុស្សជាច្រើន ក្នុងសាកលវិទ្យាល័យ ដែលម្នាក់ៗសុទ្ធតែស្លៀកពាក់ឯកសណ្ឋានទទួលសញ្ញាប័ត្រ យ៉ាងហំហាន។ មើលទៅនរណាៗ ក៏មានទឹកមុខរីករាយស្រស់ស្រាយ, មានបងប្អូន ឪពុកម្ដាយ មិត្តភក្តិ មកសំដែងការអបអរសាទរ រហូតបរិវេណសាកលភូមិន្ទឆ្អៀតណែន ដោយហ្វូងមនុស្សមីដេរដាស។ ក្រឡេកទៅខាងណា ក៏ឃើញតែបាច់ផ្កាពេញដៃគ្រប់ៗគ្នា ម្នាក់ៗសង្ហាតនាំញាតិមិត្ត ថតរូបទុកជា

អនុស្សាវរីយ៍ មួយប៉ុស្តិ៍ហើយមួយប៉ុស្តិ៍ទៀត ឥតឈប់ឈរ។ ខ្ញុំសាកសួររកឈ្មោះសរ ខេមរិទ្ធ នឹងមនុស្សជាច្រើននាក់! ...រហូតដល់ទីបំផុត។

«ប្អូនប្រុស! បងសុំសួរបន្តិច តើប្អូនស្គាល់ឈ្មោះ សរ ខេមរិទ្ធឬទេ?»

«អូ៎! សរ ខេមរិទ្ធ រឿងអីមិនស្គាល់! គេរៀននៅមហាវិទ្យាល័យអក្សរសាស្ត្រ ជាមួយខ្ញុំដែរ។ នុ៎ះគេ! កំពុងឈរតែម្នាក់ឯង នៅទីនោះ!»

ខ្ញុំដើរត្រង់ចូលទៅរកតាមពាក្យណែនាំ។ ខេមរិទ្ធមានរាងខ្ពស់សង្ហា មុខមាត់ស្អាតបាត មើលហើយក៏អាចចាត់ក្នុងជំពូកប្រុសស្អាតបានដែរ, ហើយខ្ញុំក៏ច្បាស់ក្នុងចិត្តថា គឺពិតជាគេហ្នឹងហើយ ព្រោះមុខមាត់ក៏ស្រដៀងនឹងអ៊ំស្រីម្នាក់នោះដែរ។ ខ្ញុំអាចសង្កេតបានថា គេមានពន្លឺភ្នែកដែលដក់ជាប់នូវភាពសៅហ្មងបែបណាមួយនៅក្នុងចិត្ត ទាំងដែលថ្ងៃនេះគេគួរតែសប្បាយចិត្តបំផុត នៅក្នុងជីវិតរបស់គេ។ នៅក្នុងដៃខេមរិទ្ធ មានកាន់បរិញ្ញាប័ត្រដ៏គួរឲ្យមានមោទនៈ តែកុំថាឡើយផ្កាមួយបាច់ សូម្បីតែមួយទងតូចក៏គ្មានដែរ។ ខ្ញុំដើរមកឈរទល់នឹងមុខគេ ព្រមទាំងញញឹមផង។ គេក៏ញញឹមតប តែធ្វើមុខមីងមាំងទ្រង់ធ្ងល់!

«សួស្តី! ប្អូនគឺ សរ ខេមរិទ្ធ មែនទេ?»

«បាទ! គឺខ្ញុំនេះហើយ!»

«សូមចូលរួមរីករាយជាមួយផង! បងយកបាច់ផ្កានេះមកឲ្យ ម្តាយប្អូនឯងបានផ្ញើតាមបងមក!»

«បាទ! អរគុណច្រើនបង។ បើអ៊ីចឹង ម៉ែខ្ញុំគាត់មិនបានអញ្ជើញមកទេ? អូ៎! សូមទោសបងជាអ្នកណាដែរ?»

«កុំបាច់ឆ្ងល់អី! ចាត់ទុកថាបង ជាបងប្រុសរបស់ប្អូនទៅបានហើយ! ហើយបងមកនេះគឺដើម្បីមកសម្តែងភាពរីករាយជាមួយប្អូន... តោះ! ទៅថតរូបជាមួយគ្នា។»

ខ្ញុំស្រែកហៅអ្នកថតរូប ដែលនៅឈរក្បែរនោះមកថត ហើយក៏ប្រាប់ខេមរិន្ទឲ្យនាំមិត្តភក្តិមកថតរូបជាមួយគ្នា បានប្រមាណជាង៨ប៉ុស្តិ៍ដែរ។

«ស្រេចបាច់ហើយ! អ៊ីចឹងបងគិតថា បងគួរលាប្អូនទៅវិញហើយណ៎ា!»

ខេមរិន្ទងាកមើលមុខខ្ញុំ ទឹកភ្នែកក៏ចាប់ផ្តើមជ្រាបដក់ពេញប្រលង់ភ្នែក។ ខ្ញុំរន្ធត់ចិត្តអាណិតគេយ៉ាងខ្លាំង ហើយគេក៏រត់មកអោបខ្ញុំ ទាំងទឹកភ្នែកហូរសស្រាក់។

«អរគុណបងខ្លាំងណាស់! ខ្ញុំមិនធ្លាប់គិតសោះថា ថ្ងៃនេះខ្ញុំនឹងបានទទួលបាច់ផ្កា ហើយបានថតរូបដូចគេដូចឯងដែរទេ ព្រោះខ្ញុំគ្មានបងប្អូនដូចគេដូចឯងឡើយ។ បងអើយ! ប្អូនអរគុណបងខ្លាំងណាស់... ប្អូនមិនដឹងថា គួរតបស្នងសងគុណបងយ៉ាងណាទេ?»

ខ្ញុំព្រមទទួលស្គាល់ថា ខ្ញុំខ្លួនឯងក៏មានអារម្មណ៍សប្បាយចិត្ត ហើយពេញចិត្តជាខ្លាំង ប្រសិនបើបានខេមរិន្ទ មកធ្វើជាប្អូនប្រុសបង្កើតពិតៗ។

«បានហើយ!... បានហើយ!... ធ្វើកូនប្រុសមិនត្រូវយំទេ! មើលហ្ន៎! មិនខ្មាសស្រីៗទេអ្ហ៎!»

ខេមរិន្ទញញឹមទាំងទឹកភ្នែក ហើយជូតទឹកភ្នែកចេញភ្លាមៗ។ នៅខណៈនោះ ខ្ញុំក្រឡេកឃើញស្ត្រីចំនាស់ម្នាក់ កំពុងលួចសម្លឹងមកពួកខ្ញុំ។ គាត់ពាក់មួកជំបាំងមុខជិតឈរអែបៗនឹងរបងសាកលវិទ្យាល័យ។ គំនិតខ្ញុំបានចេញប្រតិកម្មភ្លាមៗថា ហ្នឹងហើយជាអ៊ំស្រីម្នាក់នោះ! ខ្ញុំប្រញាប់ចាប់ដៃខេមរិន្ទ ដើរយ៉ាងលឿន ហើយរត់ចេញមកក្រៅទាំងខេមរិន្ទក៏នឹកឆ្ងល់ណាស់ដែរ។ ប្រហែលជាគាត់ដឹងខ្លួនមុនថា ខ្ញុំកំពុងរត់សំដៅទៅរកគាត់ ទើបគាត់ប្រញាប់ត្រលប់ក្រោយ ដើរគេចចេញទៅយ៉ាងលឿន។

«លោកអ៊ំ! លោកអ៊ំ!... ឈប់សិន!!!»

អ៊ំស្រីម្នាក់នោះ ឈប់ស្ងៀមមួយភ្លែត តែគាត់មិនងាកមុខមកទេ។ ភ្លាមនោះដែរ ខេមរិន្ទកន្ត្រាក់ដៃចេញពីខ្ញុំ គេបន្តដើរសន្សឹមៗទៅខាងមុខស្ត្រីម្នាក់នោះ ហើយពិនិត្យមើលមុខ។

«ម៉ែ!ម៉ែ!... ហេតុអីម៉ែមិនចូលទៅក្នុង? ម៉ែដឹងទេ?... ថ្ងៃនេះកូនត្រូវការឲ្យម៉ែ មកជាទីបំផុត! ព្រោះកូនគ្មាននរណាមកជួយអបអរសាទរ ឬលើកទឹកចិត្តឡើយ។ កូនដឹង! ថាម៉ែប្ញូរហៃលជាខ្លាចរូបកូននេះខ្មាសអៀនមិត្តភក្តិ ដែលកូនមានម៉ែជាអ្នកបោសសំរាមតាមថ្នល់ ជាអ្នករើសសំនល់សំរាម និងជាអ្នកក្រតោកយ៉ាក! តែម៉ែដឹងទេ... កូនអាចរៀនបានប៉ុណ្ណេះ មិនមែនម៉ែជាអ្នកផ្តុងផ្តើម ឧបត្ថម្ភឬ? កូនមិនខ្មាសអៀននរណាទាំងអស់! កូនពេញចិត្ត សប្បាយចិត្ត ដែលបានកើតជាកូនម៉ែ!...

ខេមរិន្ទលុតជង្គង់ចុះលើកដៃទាំងពីរសន្សឹមៗមកប្រណម្យ ហើយអោនក្បាលក្រាបសំពះបាតជើងម្តាយ ទាំងទឹកភ្នែកហូរឥតឈប់។ ទិដ្ឋភាពនេះបានធ្វើឲ្យខ្ញុំ និងមិត្តភក្តិរបស់ខេមរិន្ទដែលឈរពេញទីនោះ ស្រក់ទឹកភ្នែកមកព្រមៗគ្នា, ខេមរិន្ទស្ទុះឱបម្តាយព្រមទាំងស្រែកយំ...

«ម៉ែ! កូនស្រឡាញ់ម៉ែ! កូនអាណិតម៉ែ... កូនដឹងថា ម៉ែបានធ្វើពលិកម្មច្រើនណាស់ដើម្បីកូន! ម៉ែមិនដែលត្អូញ មិនដែលថានឿយហត់ សូម្បីមួយម៉ាត់ឡើយ។ មួយជីវិតម៉ែ! ម៉ែស្ទើរតែលះបង់ដើម្បីកូនទាំងអស់ទៅហើយ។ម៉ែមិនដែលឈប់សម្រាក! ម៉ែមិនដែលរកសេចក្តីសុខសម្រាប់ខ្លួនឯងម្តងណាទេ! ពលិកម្មម៉ែធំធេងណាស់! ព្រះគុណម៉ែថ្លៃថ្លាណាស់! ទោះបើកូនខំតបស្នងយ៉ាងណា ក៏មិនអាចកាត់ថ្លៃបានដែរ។»

សម្តីខេមរិន្ទ ធ្វើឲ្យម្តាយគេរំជួលចិត្តយ៉ាងខ្លាំង មាត់គាត់ញ័រហើបតិចៗ រកនិយាយតែហាមិនរួច គឺបានត្រឹមតែហូរទឹកភ្នែកជាបន្តាល់ ជាភាសាឆ្លើយតបប៉ុណ្ណោះ។

«អឺ! ទាំងអស់គ្នាជួយទះដៃឲ្យខេមរិន្ទផង... ប្អូនៗមានដឹងទេ? ទោះបីអ្នកម្ដាយរូបនេះជាអ្នកបោសសំរាមតាមចិញ្ចើមថ្នល់ក៏ដោយ ក៏គាត់អាចទំនុកបម្រុងកូន ឲ្យរៀនរហូតចប់បរិញ្ញាប័ត្របាន! ឃើញទេ ពលិកម្មរបស់ម៉ែធំធេងប៉ុណ្ណា?»

គ្រប់គ្នាដែលនៅទីនោះ ទះដៃឡើងលាន់ប្រាវៗ សំដែងអំណរចំពោះគុណូបការៈដ៏ថ្លៃថ្លានេះៗ ថ្ងៃនេះ ជាថ្ងៃពិសេសបំផុតសម្រាប់ខ្ញុំៗ ខេមរិន្ទនិងម្ដាយ ងាកមើលមុខខ្ញុំហើយញញឹម ខ្ញុំដឹងថាពួកគេចង់អរគុណខ្ញុំៗ ខ្ញុំដើរទៅឱបពួកគេទាំងពីរ ដោយចិត្តរំភើបៗ

«នេះហើយ ជាជោគជ័យនៃបរិញ្ញាប័ត្រ ដែលបានមកពីកាកសំរាម! ខេមរិន្ទ!... តទៅមុខ ប្អូនត្រូវក្លាយជាអ្នកធ្វើការម្នាក់ដ៏ល្អ ហើយរកស៊ីចិញ្ចឹមម្ដាយ តបបុណ្យសងគុណគាត់ឲ្យសក្តិសមណ៎ា! ប្អូនដឹងទេ? គ្រួសារប្អូននឹងក្លាយជាឧទាហរណ៍ ឲ្យគ្រួសារដទៃទៀតជាច្រើន ដែលខ្វះជាគ្រួសារមានឋានៈតំណែងខ្ពស់ តែគ្មានកូនណាម្នាក់ខំរៀនសូត្រទេគឺបែរជាទៅផប់ផល់នឹងឧបាយមុខសង្គម ហើយក្លាយជាជនកាកសំណល់សង្គមទៅវិញៗ»

រៀងច័ន្ទ,ថ្ងៃទី១០,មករា,២០០៨

អ៊ីមែល: archphkai_secretwriter@yahoo.com

ប្លក់: http://archphkai.wordpress.com